**ព្រះរាជាណាចក្រ កម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៦៧ ប្រ
ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០៤
**សាលដីកា**
លេខៈ១០៥
ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ................ ជាចៅក្រម
៤-លោក ................. ជាចៅក្រម
៥-លោក ................ ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជី**
-លោក ................

**តំណាងមហាអយ្យការ**
-ឯកឧត្តម .............. ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះទលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ០៤"គ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៦១១ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៣ របស់សាលាឧទ្ធរណ៍ រវាងៈ

-ដើមចោទឈ្មោះរវ (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៥៥ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិអូរ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ។ តំណាងឲ្យប្រជាជនភូមិ អូរចំនួន៨៤គ្រួសារ ។

-ចុងចម្លើយឈ្មោះសលដ (ជាម្ចាស់បណ្តឹងសាទុក) ភេទប្រុស អាយុ៤៤ឆ្នាំ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិស្វាយសរ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ផ្ទេរសិទ្ធិឲ្យញាន់ ខាន់ និងនិល យៀ តំណាងអោយប្រជាជន១៤២ គ្រួសារ ។

**កម្មវត្ថុបណ្តឹង** ប្តឹងសុំធ្វើស្រែជាបណ្តោះអាសន្នលើផ្ទៃដីទំហំ១៥០០ម x ៩០០ម ។

-បានឃើញបណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះញាន់ ខាន់ និងនិល បៀង ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ០៤"គ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ៦៧ "ប្រ" ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ របស់ឈ្មោះរឹម រ៉ង តំណាងឱ្យប្រជាជន ចំនួន៨៤គ្រួសារ បានប្តឹងសុំដីកាសម្រេចកិច្ចការប្រញាប់ហាមឃាត់ឈ្មោះសលដ ជាតំណាងឲ្យប្រជាពលរដ្ឋភូមិស្វាយសរ ចំនួន១៤២គ្រួសារ បញ្ឈប់ការធ្វើស្រែលើផ្ទៃដីទំហំ១៥០០មx៩០០ម ស្ថិតនៅភូមិអូរ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ដីនេះប្រជាពលរដ្ឋភូមិអូរ ឃុំផ្គាំ បានប្រកបរបរធ្វើស្រែលើផ្ទៃដីស្រែទំហំ៥០០មx៩០០ម ស្ថិតនៅភូមិអូរ ឃុំផ្គាំ កាលពីឆ្នាំ១៩៩២ មិន

ដែលមានខានរហូតដល់សព្វថ្ងៃ ។ នៅអំឡុងឆ្នាំ២០០១ និង ២០០២ ប្រជាជនភូមិស្វាយសរត្រូវបាន ក្រសួងបរិស្ថានហាមឃាត់ការធ្វើស្រែនៅតំបន់អាងត្រពាំងថ្ម ទើបនាំគ្នាមកដណ្តើមដីស្រែរបស់ប្រជាជនភូមិអូរ ទៅធ្វើ ។ ក្នុងរឿងនេះ ក្នុងនាមខ្លួនជាតំណាងឲ្យប្រជាជនភូមិអូរ ចំនួន៨៤គ្រួសារ បានប្តឹងមកតុលាការ ហើយតុលាការបានសម្រេចឲ្យសេចក្តីឲ្យខ្លួនជាតំណាងប្រជាជនកាន់កាប់ និងបង្កបង្កើនផល តែត្រូវភាគីសលដ ប្តឹងឧទ្ធរណ៍លុះដល់ថ្ងៃទី១៥-៥-២០០៣ ប្រជាជនភូមិស្វាយសរ ដឹកនាំដោយឈ្មោះសលដ និងមេភូមិផ្តាំ មកភ្ជួររាស់លើដីស្រែទាំងមូលនេះម្តងទៀត ។

-បានឃើញដីកាកិច្ចការប្រញាប់លេខ០៣ ដ"ប្រ" ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹងសុំកិច្ចការប្រញាប់ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ របស់ដើមចោទឈ្មោះរឹម រ៉ង ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិចុះថ្ងៃទី០៤ខែមិថុនាឆ្នាំ២០០២របស់ប្រជាជនភូមិអូរទាំង៨៤គ្រួសារឲ្យឈ្មោះរឹម រ៉ង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ។

៣-ទទួលស្គាល់លិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០២ របស់ប្រជាជនភូមិស្វាយសរ ទាំង១៤២គ្រួសារឲ្យឈ្មោះសលដ ទុកជាត្រឹមត្រូវតាមច្បាប់ ។

៤-អនុញ្ញាតឲ្យប្រជាជនភូមិអូរ ដែលមានឈ្មោះរឹម រ៉ង ជាតំណាងផ្ទេរសិទ្ធិប្រជាជនភូមិអូរបង្កបង្កើនផលលើដីស្រែទំនាស់ទំហំ១៥០០មx៩០០ម ស្ថិតនៅភូមិអូរ ឃុំផ្តាំស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ជាបណ្តោះអាសន្នបន្តទៀតរហូតដល់តុលាការសម្រេចដល់អង្គសេចក្តីចូលជាស្ថាពរ ។

៥-កាត់យកប្រាក់ប្រដាប់ក្តីកិច្ចការប្រញាប់ចំនួន២០០០៛ ដែលដើមចោទបានបង់ទុករួចហើយ ។

ដីការនេះសម្រេចចំពោះមុខគូភាគី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

-បានឃើញបណ្តឹងឧទ្ធរណ៍លខ៤៩ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះសលដ ប្តឹងមិនសុខចិត្តនឹងដីកាសម្រេចកិច្ចការប្រញាប់លេខ០៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ ត្រង់ចំណុចទី៤ ដែលអនុញ្ញាតឲ្យប្រជាជនភូមិអូរធ្វើស្រែជាបណ្តោះអាសន្ន ។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ០៤ "គ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់ សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៣ របស់ឈ្មោះសលដ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ និងគតិច្បាប់ ។

២-តម្កល់ដីកាសម្រេចកិច្ចការប្រញាប់លេខ០៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៣ របស់តុលាការខេត្តបន្ទាយមានជ័យ ទុកជាបានការដដែល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ ចំនួន១៣០០០៛ គឺពន្ធចុះបញ្ជីក្តី និងពន្ធនឹង២,៥៥០រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើកកិច្ចប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥០០០៛ សរុប១៣០០០៛ ។

-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងមេធាវីតំណាងឲ្យចុងចម្លើយ ។ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញបណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះញាន់ ខាន់ និងនិល យៀ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ០៤"គ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ ត្រង់ចំណុច ទាំងមូលនៃសេចក្តីសម្រេច ។

-បានឃើញសារណា ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះញាន់ ខាន់ តំណាងឲ្យប្រជាជន១៤២គ្រួសារ ។

-បានឃើញសារណាឆ្លើយតបចុះថ្ងៃទី២០ ខែកុម្ភៈឆ្នាំ២០០៤ របស់ឈ្មោះរឹម រ៉ង តំណាងឲ្យប្រជាជន៨៤ គ្រួសារ ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖ សាលដីការដ្ឋប្បវេណីលេខ០៤ "គ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះមានលក្ខណៈខុសឆ្គងនឹងអង្គច្បាប់ ។

-បានស្តាប់ចម្លើយរបស់ឈ្មោះញាន់ ខាន់ (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលសវនាការថាខ្លួនតំណាងឱ្យប្រជាពលរដ្ឋ១៤២គ្រួសារ សុំបន្តធ្វើស្រែលើដីទំនាស់តាមទំហំដាក់ស្តែងដូចក្រុមប្រឹក្សាឃុំ បានសម្រេចកន្លងមក ។

-បានស្តាប់ចម្លើយរបស់ឈ្មោះរឹម រ៉ង (ជាចុងបណ្តឹងសាទុក្ខ) នៅពេលសវនាការថា ខ្លួនជាតំណាងឱ្យប្រជាជន៨៤ គ្រួសារ សុំធ្វើស្រែលើដីទំនាស់ទាំងអស់ ពីព្រោះដីស្រែនេះជារបស់ភូមិអូរជាអ្នកធ្វើកន្លងមក ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រីស៊ិន ស៊ីវ៉ាន ជាមេធាវីការពារឱ្យចុងចម្លើយនៅពេលសវនាការថា៖ សុំឱ្យតុលាការកំពូលសម្រេចឱ្យប្រជាជនភូមិស្វាយសរ បានធ្វើស្រែលើតាមការសម្រេច របស់រដ្ឋអំណាចមូលដ្ឋាន ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថា ពាក្យបណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះញាន់ ខាន់ និងនិល យៀ ពិតជាបានធ្វើឡើងក្នុងរយៈពេលកំណត់ នៃច្បាប់ តុលាការកំពូលអាចលើក រឿងនេះមកធ្វើការជំនុំជំរះបាន ដោយយោងតាមបញ្ញត្តិនៃមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំងនិងសកម្មភាពសាលាជំរះក្តី ។

-យល់ឃើញថា ការដែលតុលាការខេត្តបន្ទាយមានជ័យ ក៏ដូចជាសាលាឧទ្ធរណ៍ដែរ ដែលបានសម្រេចជាវិធានការបណ្តោះអាសន្នប្រគល់ដីចំនាស់ទាំងមូលឱ្យទៅភាគីខាងប្រជាជនភូមិអូរ បង្កបង្កើនផលជាបណ្តោះអាសន្ន ដោយយល់ឃើញថា តាំងពីឆ្នាំ១៩៩២ មក ប្រជាជនភូមិអូរ បានបង្កបង្កើនផលមិនដែលអាក់ខានរហូតដល់ឆ្នាំ២០០១ ទើបប្រជាជនភូមិស្វាយសទៅរំលោភបង្កបង្កើន ផលនោះ ជាការខុសឆ្គងហើយ ដោយហេតុថា៖

-ដីទំនាស់ទាំងមូលដែលមានចំហំ១៥០០មx៩០០ម ដែលមានទីតាំងស្ថិតនៅភូមិប្រាសាទរៀន ឃុំផ្គាំ ស្រុកស្វាយចេកខេត្តបន្ទាយមានជ័យ តាំងពីដើមរៀងមករហូតដល់ពេលមានទំនាស់ ពុំទាន់មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា មានភា

គឺទំនាស់ណាមួយចូលកាន់កាប់មុនភាគីណាឡើយ ដោយយោងតាមរបាយការណ៍លេខ៥៩ ឃ-ផ ចុះថ្ងៃទី១៩-០៦-២០០៣ របស់មេឃុំផ្តៅ ដោយមានការយល់ព្រមពីអភិបាលស្រុក និងអភិបាលខេត្តផង ។ ដូចនេះការសម្រេចប្រគល់ឱ្យភាគី ណាមួយកាន់កាប់បណ្តោះអាសន្នតែម្នាក់ឯងលើវត្ថុទំនាស់ ដែលពីដើមឡើយមុនពេលមានទំនាស់មិនមានការកាន់ផ្តាច់មុខតែម្នាក់ឯងនោះ គឺជាការបំពាន់ទៅលើគោលការណ៍នៃវិធានការបណ្តោះអាសន្ន ដែលតម្រូវឱ្យរក្សានូវស្ថានភាព ដើមនៃវត្ថុទំនាស់នោះ ។

-យល់ឃើញថា ដើម្បីការពារផលប្រយោជន៍របស់គូភាគី ដែលមានជីវភាពប្រចាំថ្ងៃផ្សាភ្ជាប់ នឹងដីទំនាស់នេះ ដោយពេលនេះចូលដល់រដូវបង្កបង្កើនផលផងនោះ គប្បីតុលាការកំពូលសម្រេចប្រគល់សិទ្ធិជាបណ្តោះអាសន្នឱ្យប្រជាពលរដ្ឋទាំងពីរភូមិ បង្កបង្កើនផលលើដីទំនាស់ទៅតាមស្ថានភាពដែលមានក្នុងរបាយការណ៍លេខ៥៩ ឃ-ផ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៣(ឯ-៣) ធ្វើជាមូលដ្ឋាន។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ០៤"គ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់សាលាឧទ្ធរណ៍ មានលក្ខណៈខុសឆ្គងទាំងផ្នែកទម្រង់ និងគតិច្បាប់ តែដោយនេះជាវិធានការបណ្តោះអាសន្ន ដែលមិនមែនជាការសម្រេចទាក់ទងនឹងអង្គហេតុ ដូចនេះគប្បីតុលាការកំពូលសម្រេចទុកជាមោឃៈហើយសម្រេចជាថ្មី ដោយពុំចាំបាច់បង្វិលទៅសាលាឧទ្ធរណ៍ វិញ ។

## ហេតុដូចនេះ

## ទនិច្ឆ័យសេចក្តីចំពោះមុខគូភាគី

១-ទទួលពាក្យបណ្តឹងសាទុក្ខលេខ០៩ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០០៤ របស់ឈ្មោះញាន់ ខាន់ និងនិល យៀ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ០៤"គ" ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៤ របស់ សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣-សម្រេចបែងចែកដីទំនាស់ទំហំ១៥០០មx៩០០ម ស្ថិតនៅភូមិប្រាសាទរៀនឃុំផ្តៅ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ ឱ្យប្រជាជនភូមិអូរ និងប្រជាជនភូមិស្វាយសរ ក្នុងឃុំផ្តៅ បង្កបង្កើនផលជាបណ្តោះអាសន្នរង់ចាំតុលាការសម្រេចចប់ជាស្ថាពរដល់អង្គសេចក្តីតាមចំណែកដូចខាងក្រោម៖

ក/ដីស្រែទំហំ១៥០០មx៤៥០ម ផ្នែកខាងកើតប្រគល់ឲ្យប្រជាជនភូមិអូរ

ខ/ដីស្រែទំហំ១៥០០មx៤៥០ម ផ្នែកខាងលិចប្រគល់ឲ្យប្រជាជនភូមិស្វាយសរ

៤-រឹបអូសប្រាក់ប្រដាប់ក្តី ដែលចុងចម្លើយបានបង់នៅតុលាការកំពូលចំនួន១៩០០០៛ គឺៈ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩០០០រៀល ហើយតម្រូវដើមចោទសងប្រាក់ចំនួន១៩០០០រៀលនេះទៅចុងចម្លើយវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៤ ។